# មាតុបោសកគិជ្ឈជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធមាតុបោសកភិក្ខុ (ភិក្ខុដែលចិញ្ចឹមមាតា) មួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **តេ កថំ នុ ករិស្សន្តិ** ដូច្នេះជាដើម ។

រឿងរ៉ាវបច្ចុប្បន្នក្នុងជាតកនេះ នឹងមានជាក់ច្បាស់ក្នុង**សាមជាតក** (មហានិបាត) ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតត្មាត ចម្រើនវ័យធំហើយ ទុកដាក់មាតាបិតាដែលចាស់ជរា មានភ្នែកសាបសូន្យ ក្នុងគុហាភ្នំគិជ្ឈកូដ ហើយនាំសាច់គោជាដើម មកចិញ្ចឹមបីបាច់ថែរក្សាលោកទាំងពីរ ។ ពេលនោះ ក្នុងនគរពារាណសី មានព្រានព្រៃម្នាក់មិនកំណត់ហើយ ដាក់អន្ទាក់ចាប់ត្មាត ក្នុងព្រៃស្មសាន ។

ថ្ងៃមួយ ព្រះពោធិសត្វកាលស្វែងរកសាច់គោជាដើម បានចូលទៅកាន់ព្រៃស្មសាន ហើយក៏ជាប់អន្ទាក់ត្រង់ជើង លោកមិនបានគិតពីខ្លួនឡើយ រលឹកដល់មាតាបិតាដែលចាស់ខ្វាក់ភ្នែកថា តើនរណាហ្ន៎ នឹងចិញ្ចឹមមាតាបិតារបស់ខ្ញុំ កាលពួកគាត់មិនដឹងភាពជាអ្នកជាប់អន្ទាក់របស់ខ្ញុំ ពួកគាត់នឹងអនាថា មិនមានទីពឹង ហើយស្គាំងស្គម នឹងស្លាប់ក្នុងគុហាភ្នំ ដូច្នេះ កាលនឹងត្អូញត្អែរ ទើបពោលគាថាទី ១ ថា

**តេ កថំ នុ ករិស្សន្តិ, វុឌ្ឍា គិរិទរីសយា;**
**អហំ ពទ្ធោស្មិ ចាសេន, និលីយស្ស វសំ គតោ។**

មាតាបិតាទាំងនោះចាស់ អាស្រ័យនៅពួដ៏ច្រកនៃភ្នំ នឹងធ្វើដូចម្តចហ្ន៎ អាត្មាអញជាប់អន្ទាក់ លុះអំណាចនេសាទបុត្ត ឈ្មោះនិលីយៈហើយ ។

ពាក្យថា **និលីយៈ** បានដល់ នេសាទបុត្រដែលមានឈ្មោះយ៉ាងនោះ ។

លំដាប់នោះ នេសាទបុត្រស្តាប់សំឡេងយំខ្សឹកខ្សួលរបស់ស្តេចត្មាតហើយ ទើបពោលគាថាទី ២ ថា

**កឹ គិជ្ឈ បរិទេវសិ, កា នុ តេ បរិទេវនា;**
**ន មេ សុតោ វា ទិដ្ឋោ វា, ភាសន្តោ មានុសឹ ទិជោ។**

ម្នាលត្មាត ហេតុដូចម្តេច ក៏បានជាអ្នកខ្សឹកខ្សួល ការខ្សឹកខ្សួលរបស់អ្នក ដូចម្តេចហ្ន៎ បក្សីចេះនិយាយសំដីមនុស្ស យើងមិនដែលឮ មិនដែលឃើញសោះឡើយ ។

គិជ្ឈពោធិសត្វពោលថា

**ភរាមិ មាតាបិតរោ, វុឌ្ឍេ គិរិទរីសយេ;**
**តេ កថំ នុ ករិស្សន្តិ, អហំ វសំ គតោ តវ។**

យើងចិញ្ចឹមមាតាបិតាចាស់ អាស្រ័យនៅពួដ៏ច្រកនៃភ្នំ យើងលុះក្នុងអំណាចអ្នកហើយ មាតាបិតាទាំងនោះ នឹងធ្វើដូចម្តេចហ្ន៎ ។

*នេសាទព្រានពោលថា*

យំ នុ គិជ្ឈោ យោជនសតំ, កុណបានិ អវេក្ខតិ;
កស្មា ជាលញ្ច បាសញ្ច, អាសជ្ជាបិ ន ពុជ្ឈសិ។

*ត្រែងត្មាត រមែងមើលឃើញសាកសព ចម្ងាយ ១០០ យោជន៍ បានឬ ចុះហេតុអ្វី បានជាអ្នកមកជាប់លប់ និងអន្ទាក់ ក៏មិនភ្ញាក់ខ្លួនសោះ ។*

*ស្ដេចត្មាតពោលថា*

យទា បរាភវោ ហោតិ, បោសោ ជីវិតសង្ខយេ;
អថ ជាលញ្ច បាសញ្ច, អាសជ្ជាបិ ន ពុជ្ឈតិ។

*ពេលណាដែលមានសេចក្ដីវិនាស (មកដល់) ពេលនោះ សត្វដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់ និងអន្ទាក់ ក៏គង់មិនអាចភ្ញាក់ខ្លួនបាន ។*

*(នេសាទបុត្តពោលថា)*

ភរស្សុ មាតាបិតរោ, វុឌ្ឍេ គិរិទរីសយេ;
មយា ត្វំ សមនុញ្ញាតោ, សោត្ថិំ បស្សាហិ ញាតកេ។

*អ្នកចូរទៅចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅឯជ្រោកនៃភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅជួបនឹងពួកញាតិសន្តាន ដោយសួស្ដីចុះ ។*

*(ពោធិសត្វពោលថា)*

ឯវំ លុទ្ទក នន្ទស្សុ, សហ សព្ពេហិ ញាតិភិ;
ភរិស្សំ មាតាបិតរោ, វុឌ្ឍេ គិរិទរីសយេ។

*ម្នាលព្រាន អ្នកចូររីករាយជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនេះចុះ យើងនឹងចិញ្ចឹមមាតាបិតាចាស់ ដែលអាស្រ័យនៅឯជ្រោកនៃភ្នំ ។*

ពាក្យថា **ក្រែងគ្នាត រមែងមើលឃើញសាកសព ចម្ងាយ ១០០ យោជន៍** សេចក្ដីថា ត្មាត រមែងឃើញសាកសព សូម្បីដែលបិតនៅ ដោយការកន្ទង់ទៅ ១០០ យោជន៍ ប្រសិនបើយ៉ាង នោះ ព្រោះហេតុអ្វី បានជាអ្នកមកជាប់សំណាញ់និងអន្ទាក់នេះ អ្នកមិនដឹងឬ អ្នកមកកាន់ កន្លែងនេះ ដោយមិនដឹងឬ ។

ពាក្យថា **អ្នកចូរទៅចិញ្ចឹមមាតាបិតា** សេចក្ដីថា នេសាទព្រាននោះស្ដាប់ធម្មកថារបស់ ព្រះពោធិសត្វហើយ គិតថា ស្ដេចត្មាតនេះជាបណ្ឌិត កាលយំខ្សឹកខ្សួល មិនមែនយំដោយ គិតពីខ្លួនឯង គឺយំដើម្បីមាតាបិតា យើងមិនគួរសម្លាប់ត្មាតនេះឡើយ ដូច្នេះទើបត្រេកអរ រីករាយពោលឡើង កាលពោលហើយ ក៏ដោះអន្ទាក់ចេញដោយចិត្តជាទីស្រឡាញ់ និងចិត្ត ទន់ ។

លំដាប់នោះ ព្រះពោធិសត្វផុតពីសេចក្ដីស្លាប់ ប្រកបដោយសេចក្ដីសុខ កាលនឹងធ្វើ ការអនុមោទនា ទើបពោលគាថាចុងក្រោយ ហើយពាំសាច់ពេញមាត់ទៅជូនមាតាបិតា ។

ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក ក្នុង កាលជាទីបញ្ចប់នៃសច្ចៈ មាតុបោសកភិក្ខុ បានតាំងនៅក្នុងសោតាបត្តិផល ។

**តទា នេសាទបុត្តោ ឆន្នោ អហោសិ** នេសាទបុត្រក្នុងកាលនោះ បានមកជាឆន្នៈ

**មាតាបិតរោ មហារាជកុលានិ** មាតាបិតាបានមកជាមហារាជត្រកូល

**គិជ្ឈរាជា បន អហមេវ អហោសិំ** ចំណែកស្ដេចត្មាត គឺ តថាគតនេះឯង ។

មាតុបោសកគិជ្ឈជាតក ចប់ ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សត្តកនិបាត កុក្កុវគ្គ បិដកលេខ ៥៩ ទំព័រទី ៧៦)

ថ្ងៃ ពុធ ១២ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ០៨ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ